អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៦ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៦ (“កិច្ចប្រជុំ”) តាមរយៈប្រព័ន្ធ **Video Con-Call** នៅ**ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦** វេលាម៉ោង **១៣:០០ រសៀល** (ម៉ោងនៅភ្នំពេញ)។

**របៀបវារៈនៃកិច្ចប្រជុំនេះ ត្រូវបានកំណត់ដូចខាងក្រោម៖**

| ល.រ | របៀបវារៈ | ម៉ោង |
|---|---|---|
| **១. បើកកិច្ចប្រជុំ** | | |
| ១.១. | មតិស្វាគមន៍របស់ប្រធានមហាសន្និបាត | ១៣:០០ - ១៣:០៥ |
| ១.២. | ការណែនាំសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល | ១៣:០៥ - ១៣:១០ |
| ១.៣. | បទបង្ហាញអំពីរបៀបវារៈនៃកិច្ចប្រជុំ និងដំណើរការនៃការបោះឆ្នោត | ១៣:១០ - ១៣:១៥ |
| **២. សេចក្តីសម្រេច** | | |
| ២.១. | អនុម័តការបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញក្នុងឆ្នាំ២០២៥ និងរក្សាប្រាក់ចំណេញដែលនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុក បន្ទាប់ពីទទួលបានការអនុម័តពីនិយ័តករពាក់ព័ន្ធ | ១៣:១៥ - ១៣:២៥ |
| ២.២. | អនុម័តកាលបរិច្ឆេទកំណត់ទុកសម្រាប់ភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ | ១៣:២៥ - ១៣:៣៥ |
| ២.៣. | អនុម័តការធ្វើវិសោធនកម្មលើមាត្រា៨ ឧបសម្ព័ន្ធទី៣ និងឧបសម្ព័ន្ធទី៤ នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា | ១៣:៣៥ - ១៣:៤៥ |
| ២.៤. | អនុម័តកម្រៃសេវាសម្រាប់ក្រុមប្រឹក្សាភិបាល ២,៥០% ស្របតាមអត្រាអតិផរណាឆ្នាំ២០២៥ | ១៣:៤៥ - ១៣:៥៥ |
| ២.៥. | អនុម័តការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល | ១៣:៥៥ - ១៤:០៥ |
| ២.៦. | អនុម័តលើការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់បន្តអាណត្តិថ្មី | ១៤:០៥ - ១៤:១៥ |
| ២.៧. | អនុម័តគោលការណ៍ភាគលាភ (Dividend Policy) | ១៤:១៥ - ១៤:២៥ |
| ២.៨. | អនុម័តគោលការណ៍តែងតាំង និងលាភការ (Remuneration and Nomination Policy) | ១៤:២៥ - ១៤:៣៥ |
| ២.៩. | អនុម័តគោលការណ៍តែងតាំងអភិបាល (Director Nomination Policy) | ១៤:៣៥ - ១៤:៤៥ |
| ២.១០. | អនុម័តលើការជ្រើសរើសសវនករឯករាជ្យប្រចាំ ធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២៧ | ១៤:៤៥ - ១៤:៥៥ |
| **៣. ចំណុចដែលត្រូវពិភាក្សា និងរបាយការណ៍/បទបង្ហាញ** | | |
| ៣.១. | បទបង្ហាញ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របស់ធនាគារ អេស៊ីលីដា ដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ១៤:៥៥ - ១៥:០៥ |
| ៣.២. | របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល សម្រាប់ឆ្នាំ២០២៥ | ១៥:០៥ - ១៥:១៥ |
| ៣.៣. | របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ សម្រាប់ឆ្នាំ២០២៥ | ១៥:១៥ - ១៥:២៥ |

| ៤. ចំណុចដែលត្រូវកំណត់ចំណាំ | | |
|---|---|---|
| ៤.១. | ផ្សេងៗ | ១៥:២៥ - ១៥:៣៥ |
| ៤.២. | ប្រកាសលទ្ធផលនៃការបោះឆ្នោត | ១៥:៣៥ - ១៥:៤៥ |
| **៥. មតិបិទកម្មវិធី** | | ១៥:៤៥ - ១៦:០០ |

## ដំណើរការនៃកិច្ចប្រជុំ

### មុនពេលកិច្ចប្រជុំ

| ឯកសារ | ជំហាន-១ | ជំហាន-២ | កាលបរិច្ឆេទផ្ញើ (ម៉ោងនៅភ្នំពេញ) | |
|---|---|---|---|---|
| | | | ចាប់ពី | ដល់ |
| ១. លិខិតអញ្ជើញ | ✓ | | ២៧-មីនា-២០២៦ | ២-មេសា-២០២៦ |
| ២. លិខិតប្រគល់សិទ្ធិ | ✓ | | | |
| ៣. តំណភ្ជាប់សម្រាប់ការចុះឈ្មោះដើម្បីចូលរួមកិច្ចប្រជុំ | ✓ | | | |
| ៤. ឯកសារគាំទ្រ | ✓ | | | |
| ៥. តំណភ្ជាប់សម្រាប់ការចូលរួមកិច្ចប្រជុំ | | ✓ | ២០-មេសា-២០២៦ | ២២-មេសា-២០២៦ |
| ៦. ឃ្យូអរកូដសម្រាប់ការបោះឆ្នោត | | ✓ | | |
| ៧. សេចក្តីណែនាំអំពីការបោះឆ្នោត | | ✓ | | |

**ជំហាន-១៖** ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក**ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦** នឹងទទួលបានឯកសារក្នុងបញ្ជី**លេខ១** ដល់**លេខ៤** តាមរយៈអ៊ីម៉ែល។ ករណីដែលភាគហ៊ុនិករូបណាពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទ និងពេលវេលាកំណត់ ភាគហ៊ុនិករូបនោះអាចចាត់បុគ្គលណាម្នាក់ធ្វើជាតំណាងខ្លួន ដើម្បីចូលរួម និងបោះឆ្នោត។

***ភាគហ៊ុនិកដែលចូលរួមកិច្ចប្រជុំ AGM ត្រូវចុះឈ្មោះចូលរួមតាមតំណរភ្ជាប់ដោយផ្ទាល់ ឬអ្នកទទួលសិទ្ធិរបស់ខ្លួន និងត្រូវផ្ញើនូវលិខិតប្រគល់សិទ្ធិច្បាប់ដើមមក ភ្នាក់ងារ RTP របស់ធនាគារ អេស៊ីលីដា ចាប់ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។***

**ជំហាន-២៖** ចាប់ពី**ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦** ដល់**ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៦ ភ្នាក់ងារ RTP** នឹងផ្ញើឯកសារក្នុងបញ្ជី**លេខ៥** ដល់**លេខ៧** តាមរយៈអ៊ីម៉ែល ជូនដល់ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិ ដែលបានបំពេញតំណភ្ជាប់សម្រាប់ការចុះឈ្មោះដើម្បីចូលរួមកិច្ចប្រជុំតែប៉ុណ្ណោះ។

### បញ្ជាក់៖

- ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកសាមញ្ញ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនៅ**ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦**។
- ភាគហ៊ុនិកដែល **លក់** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ គឺនៅតែមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាត។
- ភាគហ៊ុនិកដែល **ទិញ** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦** គឺ **មិនមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតឡើយ។

**<u>កំលុងពេលកិច្ចប្រជុំ៖</u>**

- ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិម្នាក់ៗ អាចចូលរួមកិច្ចប្រជុំយ៉ាងហោច **៣០នាទីមុនពេលកិច្ចប្រជុំចាប់ផ្តើម** តាមរយៈតំណភ្ជាប់ ដែលនឹងត្រូវផ្ញើជូនដោយ **ភ្នាក់ងារ RTP** របស់ធនាគារ អេស៊ីលីដា។
- ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិម្នាក់ៗ ត្រូវបោះឆ្នោតតាមរបៀបវារៈនីមួយៗ នៃកិច្ចប្រជុំ បន្ទាប់ពីការប្រកាសរបស់ប្រធានអង្គប្រជុំ តាមរបៀបវារៈនីមួយៗ។

***សម្គាល់៖*** *ធនាគារ អេស៊ីលីដា សូមរក្សាសិទ្ធិផ្លាស់ប្តូររបៀបនៃកិច្ចប្រជុំ តាមករណីចាំបាច់ ដោយធ្វើការជូនដំណឹងជាមុន។*

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  - ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  - អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  - ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  - អ៊ីម៉ែល: op.rtp@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**